មានផ្តល់ជូនសេវាសុខភាពអាកប្បកិរិយាដោយឥតគិតថ្លៃដល់សិស្ស រដ្ឋកាលីហ្វ័រញ៉ា

# ជួយគាំទ្រដល់សុខុមាលភាពផ្លូវចិត្តកូនរបស់អ្នក — ដោយឥតគិតថ្លៃ។





សាលារៀនសាធារណៈ រដ្ឋកាលីហ្វ័រញ៉ា រួមទាំងមណ្ឌលសិក្សាធិការ កម្រិត K-12 មហាវិទ្យាល័យ និងសកលវិទ្យាល័យ – ផ្តល់សេវាសុខភាពអាកប្បកិរិយាដោយឥតគិតថ្លៃដល់សិស្ស និងក្រុមគ្រួសារ – ដោយមិនគិតថ្លៃពីអ្នក និងគ្រួសាររបស់អ្នកឡើយ។ ការជួយគាំទ្រទាំងអស់នេះមានសុវត្ថិភាព រក្សាការសម្ងាត់ និងអាចប្រើប្រាស់បាននៅក្នុងបរិវេណសាលារៀន ឬតាមរយៈកម្មវិធីរបស់សាលារៀន។

## តើការថែទាំសុខភាពអាកប្បកិរិយាជាអ្វី?

ការថែទាំសុខភាពអាកប្បកិរិយា រួមមានការជួយគាំទ្រសុខភាពផ្លូវចិត្ត និងបញ្ហាពាក់ព័ន្ធនឹងការប្រើប្រាស់សារធាតុញៀន។ សិស្សានុសិស្ស និងគ្រួសាររបស់ពួកគេអាចទទួលបានជំនួយសម្រាប់៖

» ភាពតានតឹង ការថប់បារម្ភ ឬជំងឺធ្លាក់ទឹកចិត្ត

» បញ្ហាផ្លូវអារម្មណ៍

» ការប្រើប្រាស់សារធាតុញៀន ឬការញៀនថ្នាំ

» សុខុមាលភាពផ្លូវចិត្តទូទៅ

## តើកម្មវិធីនេះដំណើរការយ៉ាងដូចម្តេចដែរ?

សាលារៀនភាគច្រើនបានផ្តល់សេវាសុខភាពផ្លូវចិត្តនេះរួចហើយ។ កម្មវិធីថ្មីរបស់រដ្ឋ - កម្មវិធីតារាងថ្លៃសេវាអាកប្បកិរិយារបស់កុមារ និងយុវជន (CYBHI) – ជួយសាលារៀនឱ្យទទួលបានប្រាក់សំណងតាមរយៈកម្មវិធីធានារ៉ាប់រងសុខភាពសម្រាប់ការផ្តល់សេវាទាំងអស់នេះដល់សិស្សដែលមានអាយុពី 0-25 ឆ្នាំ ដោយមិនគិតថាអ្នកបានទទួលអត្ថប្រយោជន៍ពីកម្មវិធី Medi-Cal មានការធានារ៉ាប់រងឯកជន ឬមានការធានារ៉ាប់រងពិការភាពនោះទេ។

## តើកម្មវិធីនេះនឹងប៉ះពាល់ដល់ការធានារ៉ាប់រងរបស់ខ្ញុំ ឬធ្វើឱ្យខ្ញុំចំណាយប្រាក់ដែរឬនោះទេ?

**អត់ប៉ះពាល់ទេ។ សេវាទាំងអស់នេះត្រូវបានផ្តល់ជូនដល់គ្រួសារដោយឥតគិតថ្លៃបន្ថែមទេ។**

» អ្នកនឹង**មិន**ត្រូវបានគិតប្រាក់ទេ។

» អ្នកនឹង**មិន**ត្រូវបង់ថ្លៃចូលរួម (co-pay) ឬថ្លៃកាត់ទុក (deductible) ណាមួយឡើយ។

» វានឹង**មិន**ប៉ះពាល់ដល់ការធានារ៉ាប់រងរបស់អ្នកឡើយ។

**សូមភ្ជាប់ទំនាក់ទំនងតាមប្រព័ន្ធផ្សព្វផ្សាយសង្គម** linktr.ee/medicaldhcs





## តើខ្ញុំត្រូវធ្វើអ្វីខ្លះ?

ប្រសិនបើកូនអ្នកមានអាយុក្រោម 18 ឆ្នាំ រៀននៅសាលាសាធារណៈ រដ្ឋកាលីហ្វ័រញ៉ា ហើយទទួលបានសេវាសុខភាពអាកប្បកិរិយានៅសាលារៀន អ្នកនឹងអាចត្រូវបានស្នើសុំឱ្យ៖

» ចុះហត្ថលេខាលើទម្រង់បែបបទនៃការយល់ព្រម

» ធ្វើបច្ចុប្បន្នភាពព័ត៌មានធានារ៉ាប់រងសុខភាពរបស់កូនអ្នក មានដូចជា៖

- ផ្តល់ច្បាប់ចម្លងបណ្ណធានារ៉ាប់រងរបស់ពួកគេ និង/ឬ
- ផ្តល់ឈ្មោះផែនការសុខភាពរបស់ពួកគេ លេខគោលនយោបាយ និងឈ្មោះរបស់អ្នក (ប្រសិនបើអ្នកជាម្ចាស់បណ្ណ)។

ប្រសិនបើអ្នកមានអាយុ 18-25 ឆ្នាំ អ្នកក៏អាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់សេវាទាំងអស់នេះផងដែរ។

## តើព័ត៌មានរបស់ខ្ញុំមានសុវត្ថិភាពទេ?

**បាទ/ចាស។ ឯកជនភាពរបស់អ្នកនឹងត្រូវបានការពារ។**

ព័ត៌មានធានារ៉ាប់រងរបស់អ្នកនឹងត្រូវបានប្រើប្រាស់ដើម្បីជួយសាលារៀនឱ្យទទួលបានការទូទាត់ប្រាក់សម្រាប់សេវាតែប៉ុណ្ណោះ។

អ្នក និងកូនអ្នកមានសិទ្ធិស្របច្បាប់ក្នុងការរក្សាការសម្ងាត់ និងការការពារក្រោមច្បាប់រដ្ឋកាលីហ្វ័រញ៉ា និងច្បាប់សហព័ន្ធ។

# សិស្សានុសិស្សគ្រប់រូបស័ក្តិសមនឹងទទួលបាននូវការថែទាំគ្រប់ៗគ្នា។

## ចូរយើងធ្វើការរួមគ្នាដើម្បីលើកកម្ពស់សុខុមាលភាពរបស់កុមារ និងយុវជនក្នុងរដ្ឋកាលីហ្វ័រញ៉ា។

**ប្រសិនបើអ្នកត្រូវការជំនួយ ឬមានសំណួរផ្សេងៗ សូមសួរអ្នកគ្រប់គ្រងសាលារៀនរបស់អ្នក ដោយចូលទៅកាន់ www.dhcs.ca.gov/CYBHI ឬផ្ញើអ៊ីមែលទៅកាន់ DHCS.SBS@dhcs.ca.gov។**

**ត្រូវការការធានារ៉ាប់រងសុខភាពមែនទេ?**

អ្នកអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់កម្មវិធី Medi-Cal។ សូមស្កេន QR កូដ នេះ ឬចូលទៅកាន់ my.medi-cal.ca.gov ដើម្បីទទួលបានការធានារ៉ាប់រងនៅថ្ងៃនេះ។